**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា)**

**កំណត់ហេតុស្តីពីកិច្ចព្រមព្រៀងការស្នើសុំព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០២០ វេលាម៉ោង ០៣:៣០ នាទីរសៀលយើងខ្ញុំដែលជាប្រតិភូបុគ្គលិកនិង ប្រធានក្រុមតំណាងឲ្យកម្មកររួមទាំងអ្នកកត់ត្រាបានចូលរួមប្រជុំ ស្តីអំពីការព្យួរកិច្ចសន្យាការងាររយៈពេល ៣២ថ្ងៃគិតចាប់ពីថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី២៥ ខែ សីហា ឆ្នាំ ២០២០។ ដោយសារតែអតិថិជនរបស់យើងនៅជប៉ុនគ្មានការកម្មង់ទំនិញដោយសារជម្ងឺកូវីត១៩ ។ បន្ទាប់មករហូតដល់ម៉ោង ៤:៣០នាទីរសៀលថ្ងៃខែឆ្នាំដដែលនៅក្នុងប្រជុំលើកទី២ មានអ្នកចូលរួមចំនួន១៥៦នាក់ ដែលក្នុងនោះមានអ្នកត្រូវព្យួរការងារមានចំនួន១១៧នាក់ យើងខ្ញុំបានពិភាក្សា និងឯកភាពគ្នារវាងកម្មករ-និយោជិតតាមការស្នើសុំរបស់ក្រុមហ៊ុន ដែលកម្មករ-និយោជិតព្យួរការងារនឹងទទួលបាននូវប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

-ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាក្នុង១ខែពីក្រុមហ៊ុន

-ទទួលបាននូវប្រាក់ឧបត្ថម្ភចំនួន៤០ដុល្លាក្នុង១ខែពីរាជរដ្ឋាភិបាល

ដើម្បីទុកជាភស្តុតាងយើងខ្ញុំជាប្រតិភូបុគ្គលិកតំណាងកម្មករនិយោជិត និងតំណាងខាងនិយោជក រួមទាំងកម្មករធ្វើការចុះហត្ថលេខារួមគ្នា។

ថ្ងៃសុក្រ ០៥រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២០

| លេខាកត់ត្រា | តំណាងនិយោជក | នាយកគ្រប់គ្រងទូទៅ |
|---|---|---|
| ឈាង ស្រីអូន | អឿន ម៉ារីណា | FU WAN TAO |

ហត្ថលេខាប្រតិភូបុគ្គលិក

| | | | |
|---|---|---|---|
| គឹម រីណា | អាន់ ចាន់ដារី | នឹម សាំងអ៊ី | សំ ម៉ៃ |